**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៣៧៩០ សហវ.ហក

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៩

**គោរពជូន**

**សម្តេចចៅហ្វាវាំង ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ គ្រប់ក្រសួង~ស្ថាប័ន គណៈអភិបាលរាជធានី និងគណៈអភិបាលគ្រប់ខេត្ត**

**កម្មវត្ថុ:** អំពីការប្រើប្រាស់សេវារថយន្តប្រណិតរបស់ក្រុមហ៊ុន Royal Cambodian Limousine Service co,. Ltd ។

**យោង:** សារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ ០៧ សរណន ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពីការប្រើប្រាស់សេវារថយន្តប្រណិត ។

តតាមន័យដូនមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមឯកឧត្តម លោកជំទាវមេត្តាជ្រាបថា ដើម្បីធានាការអនុវត្តប្រកបដោយប្រសិទ្ធភាពតាមការចង្អុលទិសរបស់រាជរដ្ឋាភិបាល ដែលបានផ្តល់សិទ្ធផ្តាច់មុខអោយក្រុមហ៊ុន Royal Cambodian Limousine Service Co., Ltd ដើម្បីផ្គត់ផ្គង់សេវារថយន្តប្រណិតជូនដល់គ្រប់ក្រសួង-ស្ថាប័ន មានជាអាទិ៍ ក្រសួង អាជ្ញាធរ ក្រុមប្រឹក្សា គណៈកម្មាធិកា គណៈកម្មាការ និងអង្គភាពនានាទាំងថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត នៃរាជរដ្ឋាភិបាល ក្នុងការដឹកជញ្ជូនគណៈប្រតិភូ និងភ្ញៀវបរទេសនានាដែលមកបំពេញ ទស្សនកិច្ចការងារនៅព្រះរាជាណាចក្រកម្ពុជានោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំលំអិតបន្ថែមលើ សារាចរណែនាំរបស់រាជរដ្ឋាភិបាលដូចតទៅ ៖

**ក-ការប្រើប្រាស់រថយន្ត:**

១- គណៈប្រតិភូ ឬភ្ញៀវបរទេសនានា ដែលជារដ្ឋមន្ត្រីឬមានឋានៈស្មើរដ្ឋមន្ត្រី ឡើងលើ សូមប្រើប្រាស់រថយន្តប្រភេទទី១ របស់ក្រុមហ៊ុនខាងលើ ។

២- គណៈប្រតិភូ ឬភ្ញៀវបរទេសនានា ដែលជារដ្ឋលេខាធិការឬមានឋានៈស្មើរដ្ឋលេខាធិការ ចុះមកដល់អគ្គនាយកឬឋានៈស្មើអគ្គនាយក សូមប្រើប្រាស់រថយន្តប្រភេទទី២ របស់ក្រុមហ៊ុនខាងលើ ។

៣- គណៈប្រតិភូ ឬភ្ញៀវបរទេសនានា ដែលមានឋានៈក្រោមអគ្គនាយក សូមប្រើប្រាស់ រថយន្តប្រភេទទី៣ របស់ក្រុមហ៊ុនខាងលើ ។

ចំពោះគ្រប់ក្រសួង-ស្ថាប័ន ដែគមានតម្រូវការប្រើប្រាស់សេវារថយន្តប្រណិត របស់ក្រុមហ៊ុនខាងលើត្រូវជូនដំណឹងទៅ “ក្រុមហ៊ុន Royal Cambodian Limousine Service Co., Ltd អាសយដ្ឋាន ផ្ទះលេខ ២៤៦ ផ្លូវព្រះមុនីវង្ស រាជធានីភ្នំពេញ ទូរស័ព្ទ ៨៥៥- ២៣ ៤២៦ ៤១៤ ទូរសារ ៨៥៥- ២៣ ៤២៦ ៤១៥” អោយបានជាមុន ០៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការ ។

វាយអត្ថបទដោយ ៖ លោក ឈឹម ទីណា

ខ- ការស្នើសុំថវិការ និងការទូទាត់:

១- ក្នុងករណីបុរេប្រទាន:

គ្រប់ក្រសួង-ស្ថាប័នដែលលើកគម្រោងចំណាយតាមរយៈថវិកាបុរេប្រទាន ត្រូវរំលេចចេញនូវការចំណាយសម្រាប់ជួលសេវារថយន្តប្រណិតខាងលើនេះ ។ ពេលស្នើសុំទូទាត់ សូមរៀបចំអាណត្តិបើកប្រាក់ដោយឡែកមួយ ដោយមានលិខិតយុត្តិការគ្រប់គ្រាន់អមជាមួយ ។

២- ក្នុងករណីសុំការទូទាត់ផ្ទាល់:

គ្រប់ក្រសួង-ស្ថាប័ន ស្នើសុំធានាចំណាយ ត្រូវរំលេចចេញនូវការចំណាយសម្រាប់ជួលសេវារថយន្តប្រណិតខាងលើនេះ ។ ដូចគ្នានឹងខាងលើដែរ ពេលស្នើសុំទូទាត់ សូមរៀបចំអាណត្តិបើកប្រាក់ដោយឡែកមួយ ដោយមានលិខិតយុត្តិការគ្រប់គ្រាន់អមជាមួយ ។

៣- មន្ទីរហិរញ្ញវត្ថុរាជធានី មន្ទីរហិរញ្ញវត្ថុគ្រប់ខេត្ត ត្រូវថតចម្លងរាល់អាណត្តិបើកប្រាក់ចំណាយសម្រាប់ជួលសេវារថយន្តប្រណិត ព្រមទាំងលិខិតយុត្តិការអមជាមួយ ហើយបញ្ជូនមកនាយកដ្ឋានហិរញ្ញកិច្ចនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាប្រចាំ ។

នាយកដ្ឋានហិរញ្ញកិច្ចនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវធ្វើការបូកសរុបប្រចាំខែនៃចំណាយប្រភេទនេះសម្រាប់ផ្ទៀងផ្ទាត់ជាមួយកិច្ចសន្យារវាងរាជរដ្ឋាភិបាលនិងក្រុមហ៊ុន Royal Cambodian Limousine Service Co., Ltd ហើយលើកវិធានការសមស្របជាយថាហេតុ ។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន គណៈអភិបាលរាជធានី គណៈអភិបាលគ្រប់ខេត្ត និងប្រធានមន្ទីរជំនាញរាជធានី ប្រធានមន្ទីរជំនាញគ្រប់ ខេត្ត សហការអនុវត្តអោយមានប្រសិទ្ធភាពខ្ពស់ ។

សូមឯកឧត្តម លោកជំទាវ មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

<u>ចម្លងជូន:</u>
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ

**ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត
- គ្រប់មន្ទីរជំនាញរាជធានី ខេត្ត
- ឯកសារនិងកាលប្បវត្តិ

វាយអត្ថបទដោយ ៖ លោក ឈឹម ទីណា